ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ
នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ

# បទបង្ហាញ

## ស្តីពី

# លទ្ធផលការងារសម្រេចបានក្នុងឆ្នាំ ២០២២ និងលើកទិសដៅការងារបន្ត របស់នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ

បង្ហាញដោយ៖ **ឯកឧត្តម ស្រ៊ិន ពុទ្ធី** ទីប្រឹក្សាក្រសួង និងជាប្រធាននាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ

ថ្ងៃអង្គារ-ពុធ ៦-៧ កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២៩-៣០ ខែវិច្ឆិកា ឆ្នាំ ២០២២

# មាតិកា



I. សេចក្តីផ្តើម

II. រចនាសម្ព័ន្ធរបស់នាយកដ្ឋាន

III. ថវិកាកម្មវិធី

IV. គម្រោងកម្មវិធីអភិវឌ្ឍន៍ផ្នែកផ្គត់ផ្គង់សេវាកម្មទឹកស្អាត និងអនាម័យជនបទ ជំហានទី ៣ (TRWSS-SDP) របស់ធនាគារអភិវឌ្ឍន៍អាស៊ី ADB

V. គម្រោងហិរញ្ញប្បទាន យូនីសេហ្វ (UNICEF)

VI. គម្រោងភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងសង្គមស៊ីវិលដើម្បីផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ជនបទ (CCCA)

VII. វឌ្ឍនភាពការងាររបស់ក្រុមការងារការផ្គត់ផ្គង់ទឹក ភាសំអាត និងអនាម័យជនបទ (WATSAN)

VIII. បញ្ហាប្រឈម

IX. ទិសដៅការងារបន្ត

# I. សេចក្តីផ្តើម

ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្រក្នុងតំបន់ជនបទ នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងលើកកម្ពស់សុខភាពសាធារណៈ និងស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេស ស្ត្រី កុមារ និងជនងាយរងគ្រោះ នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ ដែលជាសេនាធិការរបស់ក្រសួងអភិវឌ្ឍន៍ជនបទ បានខិតខំប្រឹងប្រែងអនុវត្តកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាល តាមរយៈការផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យជនបទ ដោយបានដាក់ចេញនូវទស្សនៈវិស័យ **"នៅឆ្នាំ ២០២៥ ប្រជាពលរដ្ឋគ្រប់រូបនៅសហគមន៍ជនបទ ត្រូវទទួលបានសេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យគ្រប់គ្រាន់ ព្រមទាំងរស់នៅក្នុងបរិស្ថានដែលមានអនាម័យប្រកបដោយនិរន្តរភាព"**។

# II. រចនាសម្ព័ន្ធរបស់នាយកដ្ឋាន

- នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ មានការិយាល័យ ចំនួន ០៥ គឺការិយាល័យកិច្ចការទូទៅ ការិយាល័យផ្គត់ផ្គង់ និងហិរញ្ញកិច្ច ការិយាល័យទឹកស្អាត ការិយាល័យគម្រោង និងផែនការ និងការិយាល័យប្រព័ន្ធស្រោចស្រព និងថាមពលខ្នាតតូច
- ក្របខ័ណ្ឌមន្ត្រីរាជការសរុប ចំនួន ៦០ រូប (ស្រី ១២ រូប) ដែលបានបែងចែកទៅតាមមុខងារ និងតួនាទី រួមមាន៖ ថ្នាក់ដឹកនាំនាយកដ្ឋាន ចំនួន ១១ រូប ថ្នាក់ដឹកនាំការិយាល័យ ចំនួន ២៥ រូប និងមន្ត្រី ចំនួន ២៤ រូប។



# III. ថវិកាកម្មវិធី

| កម្មវិធីទី ២៖ ការកែលម្អលក្ខខណ្ឌរស់នៅសហគមន៍ជនបទ | ថវិកាឆ្នាំ ២០២១ | ថវិកាឆ្នាំ ២០២២ | ថវិកាឆ្នាំ ២០២៣ |
|---|---|---|---|
| ច្បាប់ថវិកា | 6,256.6 | | |
| ក្រោយវិចារណកម្ម | 6,057.2 | 6,257.2 | 6,207.2 |
| អនុកម្មវិធី ២.១៖ ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតជនបទ | | | |
| ច្បាប់ថវិកា | 5,605.7 | 5,805.7 | 5,755.7 |
| ក្រោយវិចារណកម្ម | 5,605.7 | 5,805.7 | 5,750.7 |
| អនុកម្មវិធីទី ២.២៖ ការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ទឹកស្អាត | | | |
| ច្បាប់ថវិកា | 651.0 | | |
| ក្រោយវិចារណកម្ម | 451.5 | 451.5 | 451.5 |

# III. ថវិកាកម្មវិធី (ត)



| | ឈ្មោះ កម្មវិធី/អនុកម្មវិធី | ផែនការសកម្មភាព ឆ្នាំ ២០២២ | ទីតាំងភូមិសាស្ត្រ | ផែនការសកម្មភាព ឆ្នាំ ២០២៣ | ទីតាំងភូមិសាស្ត្រ |
|---|---|---|---|---|---|
| កម្មវិធីទី ២ ៖ កែលម្អលក្ខខណ្ឌ នៃការរស់នៅរបស់សហគមន៍ជនបទ | | | | | |
| អនុកម្មវិធីទី ២.១៖ ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតជនបទ | | | | | |
| ១ | ច.សះ ២.១.១៖ ការសាងសង់អណ្តូងគ្រប់ប្រភេទ | ៣០៦ អណ្តូង | ២៣ រាជធានី ខេត្ត | ៣៤៩ អណ្តូង | ២៣ រាជធានី ខេត្ត |
| ២ | ច.សះ ២.១.២៖ ការសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត | | | | |
| | ស.កះ ២.១.២.១៖ ការសាងសង់/ស្តារស្រះសហគមន៍ | ១០ ស្រះ | ចំនួន ០៨ រាជធានី ខេត្ត រួមមាន ៖ រាជធានីភ្នំពេញ តាកែវ កំពង់ស្ពឺ កំពត កោះកុង ពោធិ៍សាត់ ឧត្តរមានជ័យ និងព្រះវិហារ | ០៦ ស្រះ | ចំនួន ០៦ ខេត្ត រួមមាន៖ ខេត្តតាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង ឧត្តរមានជ័យ ព្រះវិហារ និងខេត្តពោធិ៍សាត់ |
| | ស.កះ ២.១.២.២៖ ការសាងសង់អាងត្រងទឹកភ្លៀង | ៤៩ អាង | ខេត្តមណ្ឌលគិរី និងខេត្តរតនគិរី | ៣៨ អាង | ខេត្តមណ្ឌលគិរី និងខេត្តរតនគិរី |
| | ស.កះ ២.១.២.៣៖ ការសាងសង់ប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ | ០៥ កន្លែង | ចំនួន ០៥ ខេត្ត រួមមាន៖ ខេត្តកណ្តាល កោះកុង បន្ទាយមានជ័យ ប៉ៃលិន និងខេត្តឧត្តរមានជ័យ | ០៤ កន្លែង | ចំនួន ០៤ ខេត្ត រួមមាន៖ ខេត្តបន្ទាយមានជ័យ កណ្តាល ព្រះវិហារ និងខេត្តប៉ៃលិន |
| | ស.កះ ២.១.២.៤៖ ការសាងសង់ស្ថានីយ៍ទឹកផឹកដបសហគមន៍ | ០១ កន្លែង | ខេត្តព្រៃវែង | ០១ កន្លែង | ខេត្តព្រៃវែង |
| | ស.កះ ២.១.២.៥៖ ការសាងសង់ធុងចម្រោះទឹកស្អាត | | | | |
| ៣ | ច.សះ ២.១.៣៖ ការសាងសង់/ស្តារប្រព័ន្ធស្រោចស្រព និងថាមពលខ្នាតតូច | | | | |

# III. ថវិកាកម្មវិធី (ត)



| ឈ្មោះ កម្មវិធី/អនុកម្មវិធី | | ផែនការសកម្មភាព ឆ្នាំ ២០២២ | ទីតាំងភូមិសាស្ត្រ | ផែនការសកម្មភាព ឆ្នាំ ២០២៣ | ទីតាំងភូមិសាស្ត្រ |
|---|---|---|---|---|---|
| កម្មវិធីទី ២ ៖ កែលម្អលក្ខខណ្ឌ នៃការរស់នៅរបស់សហគមន៍ជនបទ | | | | | |
| អនុកម្មវិធីទី ២.២៖ ការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ទឹកស្អាត | | | | | |
| ១ | ច.សះ ២.២.១៖ បណ្តុះបណ្តាលបច្ចេកទេស ថែទាំ និងជួសជុលអណ្តូងទឹក | ០៣ លើក | រាជធានីភ្នំពេញ | ០៣ លើក | រាជធានីភ្នំពេញ និងខេត្តស្ទឹងត្រែង |
| ២ | ច.សះ ២.១.២៖ អប់រំប្រជាជនឱ្យយល់ដឹងអំពីការប្រើប្រាស់ទឹកស្អាត | ០៣ លើក | ខេត្តបាត់ដំបង និងប៉ៃលិន | ០៣ លើក | រាជធានីភ្នំពេញ និងខេត្តស្វាយរៀង |
| ៣ | ច.សះ ២.២.៣៖ ប្រារព្ធទិវាទឹកពិភពលោក | | | | |
| ៤ | ច.សះ ២.២.៤៖ រៀបចំផែនការសុវត្ថិភាពទឹកជនបទ | ០៦ លើក | រាជធានីភ្នំពេញ និងខេត្តតាកែវ | ០៦ លើក | រាជធានីភ្នំពេញ ខេត្តបាត់ដំបង និងតាកែវ |
| ៥ | ច.សះ ២.២.៥៖ ត្រួតពិនិត្យ តាមដានការងារទឹកស្អាតជនបទ | ២៥ រាជធានី ខេត្ត | ២៥ រាជធានី ខេត្ត | ២៥ រាជធានី ខេត្ត | ២៥ រាជធានី ខេត្ត |

# សកម្មភាពក្រុមការងារនាយកដ្ឋានចុះត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ការងារសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ (ថវិកាកម្មវិធី)













unicef for every child

FTB

HTS water Pipes

TCU

AGENDA FOR CHANGE

water.org

Australian Aid

THE AUSTRALIAN WATER PARTNERSHIP

PPIAF Enabling Infrastructure Investment

CAP RED

WaterAid

# IV. គម្រោងកម្មវិធីអភិវឌ្ឍន៍ផ្នែកផ្គត់ផ្គង់សេវាកម្មទឹកស្អាត និងអនាម័យជនបទ ជំហានទី ៣ ( ADB )



**គម្រោងកម្មវិធីអភិវឌ្ឍន៍ផ្នែកផ្គត់ផ្គង់សេវាកម្មទឹកស្អាត**
**និងអនាម័យជនបទ ជំហានទី ៣ ( TRWSS-SDP )**
ADB Loan 3832/3833 and Grant 0670/0671-CAM






## IV. គម្រោងកម្មវិធីអភិវឌ្ឍន៍ផ្នែកផ្គត់ផ្គង់សេវាកម្មទឹកស្អាត និងអនាម័យជនបទ ដំណាក់កាលទី ៣ (ADB)



### ១. សង្ខេបគម្រោង

គម្រោងកម្មវិធីអភិវឌ្ឍន៍ផ្នែកផ្គត់ផ្គង់សេវាកម្មទឹកស្អាត និងអនាម័យជនបទដំណាក់កាលទី ៣ មានរយៈពេលប្រាំឆ្នាំ ដោយត្រូវបានចុះហត្ថលេខានៅថ្ងៃទី ៣០ ខែតុលា ឆ្នាំ ២០១៩ និងបានចូលជាធរមាននៅថ្ងៃទី ៦ ខែធ្នូ ឆ្នាំ ២០១៩ និងចាប់ផ្តើមអនុវត្តន៍សកម្មភាពចាប់ពីខែមករា ឆ្នាំ ២០២០ ហើយបិទបញ្ចប់គម្រោងនៅថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០២៤ ដោយទទួលឥណទានសម្បទានពី ADB ចំនួន 36,9 លានដុល្លារអាមេរិក ក្នុងនោះហិរញ្ញប្បទានរបស់ ADB: 29.61 លានដុល្លារអាមេរិក ហិរញ្ញប្បទានឥតសំណងរបស់ ADB 4.39 លានដុល្លារអាមេរិក ថវិកាបដិភាគចំនួន 2,9 លានដុល្លារអាមេរិក។

គម្រោងបានចូលរួមយ៉ាងសំខាន់ក្នុងការកែលម្អ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មផ្គត់ផ្គង់ទឹកស្អាតជនបទ កែលម្អ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មអនាម័យជនបទ ពង្រឹងសមត្ថភាពស្ថាប័នលើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ជនបទនៅខេត្តគោលដៅចំនួន ១០ គឺ៖ បន្ទាយមានជ័យ បាត់ដំបង កំពង់ឆ្នាំង កំពង់ធំ ពោធិ៍សាត់ សៀមរាប កំពង់ស្ពឺ កំពត ព្រះវិហារ និងឧត្តរមានជ័យ។

# IV. គម្រោងកម្មវិធីអភិវឌ្ឍន៍ផ្នែកផ្គត់ផ្គង់សេវាកម្មទឹកស្អាត និងអនាម័យជនបទ ជំហានទី ៣ (ADB) (ត)

## ២. សមាសភាគ និងសមិទ្ធផលសម្រេចបានរបស់គម្រោង

12

**ក) សមាសភាគទី ១៖ ការធ្វើឲ្យប្រសើរឡើង និងពង្រីកហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ**

១. **ការងារជីកស្រះសហគមន៍៖** ស្រះចំនួន ២១ សម្រាប់ Batch ១ ចំនួន ១៥ ស្រះ សម្រាប់ Batch ២ ក្រុមហ៊ុនម៉ៅការបានសាងសង់រួចរាល់ ១០០% និងស្តារស្រះ ចំនួន ០៤ ស្រះ សម្រាប់ Batch ៣ បានចំនួន ៥០% ។

២. **ការងារជួសជុលអណ្តូងខួង និងអណ្តូងលូ៖** អណ្តូងជួសជុលចំនួន ១០១ អណ្តូង (ក្នុងនោះ អណ្តូងខួងចំនួន ៣១ និងអណ្តូងលូចំនួន ៧០) សម្រាប់ Batch ១ ក្រុមហ៊ុនម៉ៅការបានធ្វើការជួសជុលរួចរាល់ ១០០%។ សម្រាប់ Batch ២ ក្រុមហ៊ុនម៉ៅការ បានបញ្ចប់ការងារជួសជុលអណ្តូងខួងចំនួន ៧១ អណ្តូង (៩៣%)។ សម្រាប់ Batch ៣ មានអណ្តូងចំនួន ១៨ នឹងត្រូវជួសជុល។

៣. **ការងារខួង និងសាងសង់អណ្តូងថ្មី៖** អណ្តូងខួងថ្មីចំនួន ៧៥៤ អណ្តូង សម្រាប់ Batch ១ និង ចំនួន ៩០៩ អណ្តូង សម្រាប់ Batch ២ ក្រុមហ៊ុនម៉ៅការបានសាងសង់រួចរាល់ ១០០% ។ សម្រាប់ Batch ៣ មានអណ្តូងខួងថ្មីចំនួន ៦៨៥ អណ្តូង សាងសង់បានចំនួន ៦៥៥ អណ្តូង ។

៤. **ការងារផលិតពាងត្រងទឹកភ្លៀងគ្រួសារ៖** ពាងចំនួន ៤៥ ២១១ សម្រាប់ Batch ១ និង ចំនួន ៣៦ ៤១៧ ពាង សម្រាប់ Batch ២ ក្រុមហ៊ុនម៉ៅការបានផលិតគ្រប់ចំនួន ១០០% ហើយបានដឹកជញ្ជូនដល់ផ្ទះអ្នកទទួលផលបានរួចរាល់។ សម្រាប់ Batch ៣ ពាងត្រងទឹកភ្លៀងចំនួន ៣៥ ៣៨៨ ពាង និងគិតត្រឹម ខែកញ្ញា ឆ្នាំ ២០២២ នេះ ក្រុមហ៊ុនម៉ៅការ ផលិតពាងបានចំនួន ៣០ ១៩២ និងបានដឹកជញ្ជូនដល់ផ្ទះប្រជាពលរដ្ឋ។

៥. **ការងារសាងសង់ប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍៖** ប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ចំនួន ០២ ទីតាំង សម្រាប់ Batch ១ ក្រុមហ៊ុនម៉ៅការបានសាងសង់រួចរាល់ ១០០% និង សម្រាប់ Batch ៣ មានប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ចំនួន ០៤ កន្លែង និងគិតត្រឹម ខែកញ្ញា ឆ្នាំ ២០២២ នេះ ក្រុមហ៊ុនម៉ៅការ សាងសង់ប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍បានប្រមាណ ៩៥% ។

៦. **ការងារសាងសង់អាងត្រងទឹកភ្លៀង៖** អាងត្រងទឹកភ្លៀងផ្លាស្ទីកចំណុះ ១០ ០០០ លីត្រ ចំនួន ៦៧ សម្រាប់ Batch ១ និងចំនួន ៧៩ សម្រាប់ Batch ២ ក្រុមហ៊ុនម៉ៅការបានសាងសង់រួចរាល់ ១០០% ។

៧. **ការងារសាងសង់ស្ថានីយផលិតទឹកពីបរិយាកាស៖** ស្ថានីយផលិតទឹកពីបរិយាកាស (Air-to-Water) ដែលមានទីតាំងនៅ ០៥ ខេត្ត គឺខេត្តព្រះវិហារ ឧត្តរមានជ័យ បន្ទាយមានជ័យ បាត់ដំបង និងកំពត ក្រុមហ៊ុនម៉ៅការបានសាងសង់រោងសម្រាប់ដាក់ម៉ាស៊ីន និងកន្លែងធ្វើការរបស់ក្រុមសហគមន៍ទាំង ៥ ទីតាំងរួចរាល់ហើយ។ បច្ចុប្បន្ន គេកំពុងធ្វើតេស្តសាកល្បងពីដំណើរការប្រព័ន្ធផលិតទឹកពីបរិយាកាសទាំង ៥ ទីតាំង មុននឹងដាក់ឱ្យសហគមន៍ប្រើប្រាស់ ។

## IV. គម្រោងកម្មវិធីអភិវឌ្ឍន៍ផ្នែកផ្គត់ផ្គង់សេវាកម្មទឹកស្អាត និងអនាម័យជនបទ ដំណាក់កាលទី ៣ (ADB)

## ២. សមាសភាគ និងសមិទ្ធផលសម្រេចបានរបស់គម្រោង (ត)



**ខ) សមាសភាគទី ២៖ ការធ្វើឲ្យប្រសើរឡើង និងពង្រីកហេដ្ឋារចនាសម្ព័ន្ធសេវាកម្មអនាម័យជនបទ**

១. **ការងារសាងសង់បង្គន់គ្រួសារ៖** បង្គន់គ្រួសារចំនួន ៦ ៤៦២ សម្រាប់ Batch ១ ក្រុមហ៊ុនម៉ៅបានផ្គត់ផ្គង់ និងបានដំឡើងបង្គន់ផ្នែកខាងក្រោមជូនប្រជាពលរដ្ឋរួចរាល់ ១០០%។ សម្រាប់ Batch ២ ក្រុមហ៊ុនម៉ៅការបានសាងសង់បង្គន់គ្រួសារផ្នែក ខាងក្រោមបានចំនួន ២ ០៦៦ ក្នុងខេត្តគោលដៅទាំង ១០ ។

២. **ការងារសាងសង់បង្គន់សាធារណៈ ៖** បង្គន់សាធារណៈចំនួន ៧៨ សម្រាប់ Batch ១ និង សម្រាប់ Batch ២ ដែលមានបង្គន់សាធារណៈចំនួន ៦៩ ក្រុមហ៊ុនម៉ៅការបានសាងសង់រួចរាល់ ១០០% ។ សម្រាប់ Batch ៣ ពុំមានបង្គន់សាធារណៈដែលត្រូវសាងសង់ទេ។

# IV. គម្រោងកម្មវិធីអភិវឌ្ឍន៍ផ្នែកផ្គត់ផ្គង់សេវាកម្មទឹកស្អាត និងអនាម័យជនបទ ជំហានទី ៣ (ADB)

## ២. សមាសភាគ និងសមិទ្ធផលសម្រេចបានរបស់គម្រោង (ត)



**គ) សមាសភាគទី ៣៖** ការអភិវឌ្ឍសមត្ថភាពមន្ត្រីគ្រប់គ្រង និងអនុវត្តគម្រោង និងការអប់រំ ផ្សព្វផ្សាយសហគមន៍

**១. ការអភិវឌ្ឍសមត្ថភាពមន្ត្រីគ្រប់គ្រង និងអនុវត្តគម្រោង៖** ក្នុងខែឧសភា ឆ្នាំ ២០២២ គម្រោងបានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីរបៀបអង្កេតផលប៉ះពាល់ក្នុង Batch ទី ១ ចំនួន ០២ វគ្គ ដល់មន្ត្រីអនុវត្តគម្រោងថ្នាក់ជាតិ (PCU) មន្ត្រីអនុវត្តគម្រោងថ្នាក់ខេត្ត (PPT) និងក្រុមទីប្រឹក្សាគម្រោងថ្នាក់ខេត្ត (NKEs) ។

**២. ការចុះបេសកម្មរបស់ក្រុមសម្របសម្រួលគម្រោងថ្នាក់ជាតិ (PCU) និងក្រុមទីប្រឹក្សាគម្រោង (PIC)៖**

- ថ្ងៃទី ១៦-២០ ខែឧសភា ឆ្នាំ ២០២២ ក្រុមសម្របសម្រួលគម្រោងថ្នាក់ជាតិ និងក្រុមទីប្រឹក្សា បានចុះបេសកកម្មទៅខេត្តកំពង់ស្ពឺ កំពត កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ ព្រះវិហារ និងឧត្តរមានជ័យ ដើម្បីត្រួតពិនិត្យ និងណែនាំបច្ចេកទេសក្នុងការអង្កេតផលប៉ះពាល់របស់ Batch ទី ១ របស់មន្ត្រីអនុវត្តគម្រោងថ្នាក់ខេត្ត (PPT) និងមន្ត្រី NKEs។
- ថ្ងៃទី ២៥-៣១ ខែឧសភា ឆ្នាំ ២០២២ ក្រុមសម្របសម្រួលគម្រោងថ្នាក់ជាតិ និងក្រុមទីប្រឹក្សា បានចុះបេសកកម្មទៅខេត្តកំពង់ស្ពឺ និង ព្រះវិហារ ដើម្បីត្រួតពិនិត្យ និងណែនាំបច្ចេកទេស ដល់ការងារសាងសង់អាងប្រព្រឹត្តិកម្មទឹកស្អាតសម្រាប់ Batch ទី ២ និងកំណត់ទីតាំងសម្រាប់សាងសង់អាងប្រព្រឹត្តិកម្មទឹកស្អាត និងអាងអាកាសសម្រាប់ Batch ទី ៣ និងសិក្សាពីសំណើសាងសង់ប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ សម្រាប់ Batch ទី ៤។

## IV. គម្រោងកម្មវិធីអភិវឌ្ឍន៍ផ្នែកផ្គត់ផ្គង់សេវាកម្មទឹកស្អាត និងអនាម័យជនបទ ជំហានទី ៣ (ADB)

## ២. សមាសភាគ និងសមិទ្ធផលសម្រេចបានរបស់គម្រោង (ត)



### ៣. ការត្រួតពិនិត្យការអនុវត្តច្បាប់ការពារសុវត្ថិភាពសង្គម និងបរិស្ថាន៖

- GRM មិនមានរបាយការណ៍អំពីបណ្តឹងតវ៉ាក្នុងការអនុវត្តគម្រោងសម្រាប់ Bacth ទី ២ និងទី ៣ ទេ។
- ក្រុមការងារអនុវត្តគម្រោងថ្នាក់ខេត្ត (PPTs) និងក្រុមទីប្រឹក្សាខេត្ត (NKEs) បានចុះរៀបចំបង្កើតរចនាសម្ព័ន្ធក្រុមអ្នកទទួលបណ្តឹងតវ៉ានៅថ្នាក់ភូមិ ឃុំ និងណែនាំអំពីតួនាទី និងភារកិច្ចរបស់ពួកគាត់ នៅពេលគម្រោង Batch ទី ៣ ចាប់ផ្តើមអនុវត្តនាពេលខាងមុខរៀបចំរបាយការណ៍ត្រួតពិនិត្យ តាមដានប្រចាំខែ។

### ៤. ផែនការសកម្មភាពយេនឌ័រ (GAP)៖

- បានរៀបចំផែនការសកម្មភាពយេនឌ័រសម្រាប់គ្រប់ខេត្ត ស្រុក ឃុំ និងភូមិគោលដៅ
- ធ្វើការតាមដានការអនុវត្តផែនការសកម្មភាពយេនឌ័រខាងលើ ។

# សកម្មភាពក្រុមការងារអនុវត្តគម្រោងកម្មវិធីអភិវឌ្ឍន៍ផ្នែកផ្គត់ផ្គង់សេវាកម្មទឹកស្អាត និងអនាម័យជនបទ ជំហានទី ៣ ( ADB )













# V. គម្រោងហិរញ្ញប្បទានអង្គការ យូនីសេហ្វ

## ១. សវតារបស់គម្រោង

❖ គោលបំណងរបស់គម្រោង៖

- ✓ សម្របសម្រួលដៃគូអភិវឌ្ឍន៍
- ✓ ជួយរៀបចំផែនការ
- ✓ សុវត្ថិភាពទឹកឃុំ និងសិក្សាពីចំនុចខ្វះខាត
- ✓ ការប្រើប្រាស់ទឹកសុវត្ថិភាពក្នុងឃុំ
- ✓ ជួយគ្រួសារក្រីក្រ ឱ្យទទួលបានអាងត្រងទឹកភ្លៀង

- ឈ្មោះគម្រោង៖ កិច្ចសហការជាមួយអង្គការ យូនីសេហ្វ
- គម្រោងថវិកា៖ ១០០ ០០០ ដុល្លា
- ប្រភពថវិកា៖ អង្គការ យូនីសេហ្វ
- រយៈពេល នៃការអនុវត្តគម្រោង៖ រយៈពេល ០១ ឆ្នាំ (ចាប់ផ្តើមខែមករា ឆ្នាំ ២០២២ បញ្ចប់ខែធ្នូ ឆ្នាំ ២០២២)
- អ្នកពាក់ព័ន្ធ៖
  - នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ
  - អង្គការ Unicef
  - មន្ទីរអភិវឌ្ឍន៍ជនបទ
  - អាជ្ញាធរមូលដ្ឋាន(ស្រុក ឃុំ)

# V. គម្រោងហិរញ្ញប្បទានអង្គការ យូនីសេហ្វ
## ២. សមិទ្ធផលរបស់គម្រោងកិច្ចសហការជាមួយអង្គការ យូនីសេហ្វ

- បណ្ដុះបណ្ដាល ស្ដីពីផែនការសុវត្ថិភាពទឹកជនបទដល់មន្ទីរអភិវឌ្ឍន៍ជនបទ ទាំង ២៥ រាជធានី ខេត្ត
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្ដីពីលទ្ធផលការវាយតម្លៃការបញ្ជ្រៀបភាពធន់នឹងអាកាសធាតុ នៅក្នុងកម្មវិធីទឹកស្អាត និងអនាម័យជនបទ របស់អង្គការ យូនីសេហ្វ ដល់តំណាងមន្ទីរអភិវឌ្ឍន៍ជនបទ ទាំង ២៥ រាជធានី ខេត្ត
- សហការជាមួយមន្ទីរអភិវឌ្ឍន៍ជនបទ ដើម្បីចុះមូលដ្ឋានត្រួតពិនិត្យ និងតាមដានការងារផ្គត់ផ្គង់ទឹកស្អាតជនបទ
- ត្រួតពិនិត្យឡើងវិញ គោលការណ៍ណែនាំ ស្ដីពីផែនការសុវត្ថិភាពទឹកជនបទដែលធន់នឹងអាកាសធាតុ
- ផ្សព្វផ្សាយគោលការណ៍ណែនាំ ស្ដីពីផែនការសុវត្ថិភាពទឹកជនបទដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ
- ពិនិត្យឡើងវិញនូវសេចក្ដីព្រាង ស្ដីពីការផ្ទៀងផ្ទាត់សហគមន៍ទឹកសុវត្ថិភាព
- ធ្វើបច្ចុប្បន្នភាពផែនការសុវត្ថិភាពទឹកឃុំ នៅឃុំចំនួន ១០ ក្នុងខេត្តកំពង់ស្ពឺ និងស្វាយរៀង






# VI. គម្រោងភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងសង្គមស៊ីវិលដើម្បីផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ជនបទ (CCCA)

## ១. សង្ខេបគម្រោង



- គោលបំណងរបស់គម្រោង៖
- ✓ បង្កើនការប្រើប្រាស់ទឹកសុវត្ថិភាពនៅតាមសហគមន៍ជនបទ
- ✓ បង្កើតគោលការណ៍ណែនាំ ស្តីពីការកាត់បន្ថយផលប៉ះពាល់បណ្តាលមកពីគ្រោះរាំងស្ងួត

- ឈ្មោះគម្រោង៖ ភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងសង្គមស៊ីវិល ដើម្បីផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ជនបទ (CCCA)
- គម្រោងថវិកា៖ ៩ ៩៧០០ ដុល្លា
- ប្រភពថវិកា៖ ក្រសួងបរិស្ថាន
- រយៈពេល នៃការអនុវត្តគម្រោង៖ រយៈពេល ២៦ ខែ (ចាប់ពីខែមិថុនា ឆ្នាំ ២០២១ ដល់ខែសីហា ឆ្នាំ ២០២៣)
- អ្នកពាក់ព័ន្ធ៖
  - ក្រសួងអភិវឌ្ឍន៍ជនបទ
  - ក្រសួងបរិស្ថាន
  - មន្ទីរអភិវឌ្ឍន៍ជនបទខេត្តសៀមរាប និងបន្ទាយមានជ័យ
  - ក្រុមប្រឹក្សាឃុំគោលដៅ
  - អង្គការ ទឹកស្អាត ១០០១

# VI. គម្រោងភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងសង្គមស៊ីវិលដើម្បីផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ជនបទ (CCCA)

## ២. សមាសភាពរបស់គម្រោង



- ❖ សាងសង់ស្ថានីយផលិតទឹកផឹកជនបទ នៅខេត្តចំនួន ០២ គឺខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប
- ❖ រៀបចំគោលការណ៍ណែនាំ ស្តីពីការកាត់បន្ថយផលប៉ះពាល់ដែលបណ្តាលមកពីគ្រោះរាំងស្ងួត







# VII. វឌ្ឍនភាពការងាររបស់ក្រុមការងារការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ (WATSAN)

ក្រុមការងារផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ (WATSAN) បានប្រជុំប្រចាំខែ យ៉ាងទៀងទាត់ ដោយមានការចូលរួមពីមន្ទីរអភិវឌ្ឍន៍ជនបទទាំង ២៥ រាជធានី-ខេត្ត (ក្នុងមួយខែ ចំនួន ០២ ខេត្ត) អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍នានាដែលពាក់ព័ន្ធនឹងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ផ្តោតលើប្រធានបទ មានដូចជា៖

- ចែករំលែកព័ត៌មានពីអនុក្រុមនីមួយៗ ស្តីពីការអនុវត្តការងាររបស់អនុក្រុម ទាំង ៣
- ធ្វើបទបង្ហាញ ស្តីពីវឌ្ឍនភាពរបស់ PAP តាមបណ្តាខេត្ត ដែលបានចូលរួម
- ធ្វើបទបង្ហាញ ស្តីពីលទ្ធផលការសិក្សា ស្រាវជ្រាវ និងការអនុវត្តល្អៗក្នុងកម្មវិធី WASH
- ពិនិត្យមើលគោលការណ៍ណែនាំ និងសៀវភៅណែនាំបច្ចេកទេស (Technical Guidelines)
- ចូលរួមយ៉ាងសកម្មក្នុងដំណើរការឆ្លុះបញ្ចាំង NAP2 2019-2023
- ធ្វើរបាយការណ៍សង្ខេប ស្តីពីលទ្ធផលការងារក្រុម WATSAN ជូនកិច្ចប្រជុំត្រីមាសរបស់ TWG
- ចូលរួមក្នុងការរៀបចំទិវាទឹកពិភពលោក និងទិវាជាតិលើកកម្ពស់អនាម័យជនបទ

# VIII. បញ្ហាប្រឈម

- សកម្មភាពការងារមួយចំនួន ដូចជា ការបណ្ដុះបណ្ដាលផែនការសុវត្ថិភាពទឹកជនបទ ការជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទដល់សហគមន៍ជនបទ មិនអាចអនុវត្តទៅបានតាមការគ្រោងទុក ដោយសារតែការរាតត្បាតពីជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ទើបតែបញ្ចប់ ប៉ុន្តែ មេរោគ នៃជំងឺកូវីដ-១៩ ប្រភេទថ្មី នៅតែបន្តរីរាលដាលក្នុងសហគមន៍នៅឡើយ
- អត្រាគ្របដណ្ដប់ទឹកនៅតាមតំបន់មួយចំនួននៅមានភាគរយទាបនៅឡើយ
- ការចូលរួមរបស់សហគមន៍ និងកិច្ចសហការរបស់អង្គការ ដៃគូរអភិវឌ្ឍន៍នានាលើវិស័យផ្គត់ផ្គង់ទឹកនៅមានកម្រិត
- ការផ្លាស់ប្ដូរទម្លាប់ប្រជាពលរដ្ឋក្រីក្រជនបទនៅមានកម្រិត
- បញ្ហាបម្រែបម្រួលអាកាសធាតុនៅតែកើតមានជារឿយៗ
- អណ្ដូងមួយចំនួនត្រូវបានរីងស្ងួត និងខូចខាតដោយសារតែការប្រែប្រួលអាកាសធាតុ
- នាយកដ្ឋានពុំមានថវិកាសម្រាប់តម្កល់នៅពេលកើតមានគ្រោះមហន្តរាយភ្លាមៗ
- ពុំមានថវិកាសម្រាប់ចុះតាមដានការងារបម្រែបម្រួលអាកាសធាតុ
- នាយកដ្ឋានពុំមានថវិកាសម្រាប់ធ្វើបញ្ជីសារពើភ័ណ្ឌទិន្នន័យប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅទូទាំងប្រទេស

# IX. ទិសដៅការងារបន្ត

- បន្តកៀរគរហិរញ្ញវត្ថុ សម្រាប់ការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ
- បន្តជំរុញការធ្វើបញ្ជីសារពើភ័ណ្ឌទិន្នន័យប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទនៅទូទាំងប្រទេស
- បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការ ដៃគូអភិវឌ្ឍន៍ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់នៅជនបទ
- បន្តពង្រឹងយន្តការដឹកនាំជាមួយអាជ្ញាធរនៅថ្នាក់ក្រោមជាតិ ដោយចាត់ទុកការងារទឹកស្អាត និងអនាម័យ ជាការងារអាទិភាពសំខាន់បំផុត
- បន្តអនុវត្តផែនការសកម្មភាពជាតិ ផែនការយុទ្ធសាស្ត្រជាតិ និងគោលនយោបាយជាតិ
- បន្តជំរុញការលើកកម្ពស់ និងអប់រំផ្សព្វផ្សាយអំពីការប្រើប្រាស់ និងថែទាំប្រភពទឹក
- បន្តត្រួតពិនិត្យ តាមដាន និងវាយតម្លៃប្រព័ន្ធផ្គតផ្គង់ទឹកស្អាតជនបទ
- បន្តធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះក្រុមហ៊ុនខួងអណ្តូងឯកជន
- បន្តត្រួតពិនិត្យគុណភាពទឹកតាមស្តង់ដាររបស់គោលការណ៍ណែនាំ ស្តីពីគុណភាពទឹកផឹកជនបទ

# សូមអរគុណ
# ចំពោះការយកចិត្តទុកដាក់ស្តាប់